**គោរពជូនសម្តេចពញាចក្រី ហេង សំរិន**

ប្រធានរដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៥

## ស្នើសុំដកសេចក្តីព្រាងច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល

សម្តេចជាទីគោរពរាប់អាន!

យើងខ្ញុំទាំងអស់គ្នា តំណាងឲ្យអង្គការអន្តរជាតិ សូមអំពាវនាវដល់រដ្ឋសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា សូមមេត្តាដកចេញជាបន្ទាន់នូវសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល (LANGO)។

សេចក្ដីព្រាងច្បាប់នេះ ហាក់ដូចជាត្រូវបានរៀបចំតាក់តែងឡើងដើម្បីកំហិត សកម្មភាពស្របច្បាប់របស់អង្គការសង្គមស៊ីវិល និងអ្នកការពារសិទ្ធិមនុស្សដោយរំលោភបំពានសិទ្ធិសេរីភាពខាងសមាគម ដែលជាសិទ្ធិការពារដោយលិខិតូបករណ៍សិទ្ធិមនុស្សអន្តរជាតិ ដែលប្រទេសកម្ពុជាជាភាគីមួយ និងជាសិទ្ធិដែលការពារដោយរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្នុងដំណើរការតាក់តែងច្បាប់ដែលបានប្រព្រឹត្តទៅជាអសាធារណៈ និងមិនត្រឹមត្រូវដោយមិនមានការពិគ្រោះយោបល់ និងមិនមានការផ្ដល់នូវឱកាសក្នុងការបញ្ចេញយោបល់ទៅលើសេចក្ដីព្រាងច្បាប់នេះ ទោះជាមានការស្នើសុំជាបន្តបន្ទាប់ដោយក្រុមអង្គការសង្គមស៊ីវិលក៏ដោយ។ ការស្នើសុំឲ្យរដ្ឋាភិបាលធ្វើការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិល (#StopandConsult) ត្រូវបានធ្វើមិនដឹងមិនឮ។ សេចក្ដីព្រាងច្បាប់មិនត្រូវបានបញ្ចេញឲ្យសាធារណៈជនដឹងឮរហូតដល់សប្ដាហ៍កន្លងទៅនេះ នៅពេលដែល សេចក្ដីព្រាងច្បាប់នេះត្រូវបានចែករំលែកដោយអ្នកនាំពាក្យនៃក្រុមប្រឹក្សារដ្ឋមន្ត្រី ជាច្រើន ថ្ងៃបន្ទាប់ពីមានការលេចធ្លាយនូវសេចក្ដីព្រាងនេះ។ ដំណើរការនេះវាផ្ទុយពីបទដ្ឋានអន្តរជាតិស្ដីពីការចូលរួម។

សន្ធិសញ្ញាទាំងឡាយរបស់អង្គការសហប្រជាជាតិ និងសេចក្ដីប្រកាសស្ដីពីសិទ្ធិ និងការទទួលខុសត្រូវបុគ្គល ក្រុម និងអង្គការសង្គមដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្សជាសាកល និងសេរីភាពជាមូលដ្ឋានរបស់អង្គការសហប្រជាជាតិ (សេចក្ដីប្រកាស អង្គការសហប្រជាជាតិស្ដីពីអ្នកការពារសិទ្ធិមនុស្ស) ដែលត្រូវបានអនុម័តដោយមានការយល់ព្រមពីរដ្ឋទាំងឡាយ ក្នុងនោះរួមមានប្រទេសកម្ពុជាផងដែរ បានការពារសិទ្ធិមនុស្សគ្រប់រូបជាបុគ្គល និងការចូលរួមជាមួយអ្នកដទៃដើម្បីចូលរួមប្រកបដោយប្រសិទ្ធិភាពនៅក្នុងរដ្ឋាភិបាលនៃប្រទេសរបស់ខ្លួន និងនៅក្នុងការប្រតិបត្តិការងារសាធារណៈទាំងឡាយ។ នេះរួមមានសិទ្ធិក្នុងការដាក់ជូនដល់ស្ថាប័នរដ្ឋាភិបាលទទួលបន្ទុកនូវកិច្ចការសាធារណៈនូវការស្នើទិះតៀន និងការស្នើកែលំអការប្រព្រឹត្តទៅរបស់ស្ថាប័នទាំងនោះ ព្រមទាំងសំណើសុំឲ្យមានការយកចិត្តទុកដាក់ចំពោះទិដ្ឋភាពណាមួយនៃការងាររបស់ពួកគេ ដែលអាចរារាំងដល់ការលើកកម្ពស់ ការការពារ និងការធ្វើឲ្យសម្រេចនូវសិទ្ធិមនុស្ស និងសិទ្ធិសេរីភាពជាមូលដ្ឋានទាំងឡាយ។

សេចក្ដីព្រាងច្បាប់ស្ដីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមាន ៣៩ មាត្រា ដែលគូសបញ្ជាក់នូវរបបទ្វេរច្បាប់ (a dual regulatory regime) ដែលគ្រប់គ្រងលើក្រុមអង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិដែលស្ថិតនៅក្រោមការណែនាំពីក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយមានអាជ្ញាធរគ្រប់គ្រង និងពិនិត្យតាមដានបន្ថែមទៀតនៅក្នុងក្រសួង និងទីភ្នាក់ងារទាំងឡាយរបស់រដ្ឋាភិបាល។

ប្រសិនបើច្បាប់នេះត្រូវបានអនុម័តមែននោះ សេចក្តីព្រាងច្បាប់នេះនឹងធ្វើឲ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់តួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិល នៅក្នុងប្រទេសកម្ពុជា។ ច្បាប់នេះមានចែងនូវកាតព្វកិច្ចចុះបញ្ជីកា និងរាយការណ៍បែបការិយាល័យធិបតេយ្យស្មុគ្រស្មាញសម្រាប់អង្គការសង្គមស៊ីវិល និងគម្រាមធ្វើការត្រួតត្រា និងត្រួតពិនិត្យ (the control and censorship) ទៅលើសកម្មភាពស្របច្បាប់ទាំងឡាយដែលបានអនុវត្តដោយសមាគមក្នុងស្រុក និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទៅវិញ។

សិទ្ធិសេរីភាពខាងសមាគមត្រូវបានធានាដោយមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (ICCPR) ដែលប្រទេសកម្ពុជាគឺជារដ្ឋភាគី មួយ និងត្រូវបានធានាដោយមាត្រា ៩២ នៃរដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា។ សិទ្ធិសេរីភាពខាងសមាគមអាចត្រូវបានកម្រិតឬកំហិតក្នុងកាលៈទេសៈដែលបានកំណត់ដ៏ចង្អៀតខ្លះតែប៉ុណ្ណោះ។ មាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR) ចែងអំពីការកម្រិតតេស្ត ៣ ផ្នែក (a three-part test) ទៅលើសេរីភាពខាងសមាគម ដែលនៅក្រោមសេរីភាពនេះការកម្រិតទៅលើសិទ្ធិត្រូវបានអនុញ្ញាតលើកលែងតែវា (១) មានចែងដោយច្បាប់ដែលមានចែងច្បាស់លាស់ ហើយច្បាប់នេះគេអាចរកបាន (clear and accessible) (២) ស្របតាមផលប្រយោជន៍ ស្របច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា ២២[1] និង (៣) បង្ហាញថាវាមានភាពចាំបាច់ដោយខានមិនបាន (strictly and demonstrably necessary)។

សេចក្តីព្រាងច្បាប់នេះ មានបទប្បញ្ញត្តិមួយចំនួនដែលមិនបំពេញតាមលក្ខខណ្ឌមួយ ឬច្រើននៃផ្នែកពិសោធនកម្មទាំង ៣ នេះ ដោយរំលោភទៅលើសិទ្ធិសេរីភាពខាងសមាគម ៖

*ការចុះបញ្ជិកាសមាគម/អង្គការជាការចាប់បង្ខំដែលមានលក្ខណៈជាសាកល (Universal mandatory registration):* សេចក្តីព្រាងច្បាប់បង្គាប់ឲ្យគ្រប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិទាំងអស់ដែលធ្វើប្រតិបត្តិការនៅក្នុងប្រទេស ត្រូវចុះបញ្ជីជាការចាំបាច់ និងមានចែងអំពីការផាកពិន័យ និងការដាក់ទោសព្រហ្មទណ្ឌដល់អង្គការទាំងឡាយដែលអនុវត្តសកម្មភាពដោយមិនបានចុះបញ្ជី ហើយអ្វីជាការព្រួយបារម្ភរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិនោះ គឺពាក់ព័ន្ធជាមួយការបណ្តេញចេញនូវបុគ្គលិកបរទេស ចេញពីប្រទេសថែមទៀតផង។ ប្រការដែលគួរឲ្យកត់សម្គាល់គឺថា សេចក្តីព្រាងច្បាប់នេះវាមិនដូចសេចក្តីព្រាងច្បាប់ឆ្នាំ ២០១១ ដោយសេចក្តីព្រាងច្បាប់បច្ចុប្បន្ន មិនមានចែងអំពីអង្គការដែលមានមូលដ្ឋាននៅថ្នាក់សហគមន៍ និងមិនបានលើកលែងពួកគេចេញពីកាតព្វកិច្ចចុះបញ្ជិកា ដោយបើកចំហឲ្យមានលទ្ធភាពតម្រូវឲ្យគ្រប់ក្រុមទោះបីជាក្រុមតូច ឬក្រុមមិនផ្លូវការក្តីធ្វើការចុះបញ្ជីទាំងអស់ នៅពេលដែលសេចក្តី

[1] ផលប្រយោជន៍ស្របច្បាប់មានចែងនៅក្នុងមាត្រា ២២ គឺ "សន្តិសុខជាតិ ឬសុវត្ថិភាព និង សណ្តាប់ធ្នាប់សាធារណៈ (ordre public), ការការពារសុខភាពសាធារណៈ ឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ"។

ព្រាងនេះបានក្លាយទៅជាច្បាប់ហើយនោះ។ សិទ្ធិសេរីភាពរបស់សមាគមបានការពារសមាគមដែលមិនបានចុះបញ្ជិកា។[2] ដោយមិនបានលើកកម្ពស់នូវគោលការណ៍នេះផង សេចក្តីព្រាងច្បាប់នេះបែរជាធ្វើការដាក់ទោសដល់បុគ្គលដែលបានចូលរួមនៅក្នុងសកម្មភាពស្របច្បាប់ដែលត្រូវបានការពារនៅក្នុងការអនុវត្តសិទ្ធិទៅវិញ។

*ការដាក់កំហិតតាមទំនើងចិត្តទៅលើសមាជិកស្ថាបនិក៖* ដើម្បីបង្កើតសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលតម្រូវឲ្យមានសមាជិកស្ថាបនិកចំនួន ៥រូប អាយុគ្រប់ ១៨ឆ្នាំឡើង និងដែលមិនធ្លាប់បំពេញតួនាទីជាថ្នាក់ដឹកនាំនៃអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមដែលពីមុនត្រូវបានលុបឈ្មោះចេញពីបញ្ជី។ នេះគឺជាលក្ខខណ្ឌតម្រូវចំនួន សមាជិកដែលធ្វើតាមទំនើងចិត្ត[3] ដែលដកចេញដោយអយុត្តិធម៌ និងមិនត្រឹមត្រូវនូវប្រភេទបុគ្គលដែលមានសមត្ថភាពពីការទទួលបានសិទ្ធិសេរីភាពខាងសមាគម។ ក្នុងករណីបុគ្គលដែលមានអាយុក្រោម ១៨ឆ្នាំ សិទ្ធិសេរីភាពខាងសមាគមរបស់ពួកគេក៏ត្រូវបានធានាដោយមាត្រា ១៥ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារដែលប្រទេសកម្ពុជាជាភាគីនៃអនុសញ្ញានេះដែលសិទ្ធិនេះអាចទទួលរងនូវការកំហិតស្រដៀងនេះខ្លះដែរ ដូចដែលមានចែងនៅក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR)។

*លក្ខខណ្ឌតម្រូវឲ្យមានការចុះបញ្ជិកាដែលបង្កឲ្យមានការព្រួយបារម្ភ៖* សេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល តម្រូវឲ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិធ្វើការចុះបញ្ជីនៅក្នុងដំណើរការមួយប្រកបដោយការិយាធិបតេយ្យ និងបង្កនូវការព្រួយបារម្ភដោយតម្រូវឲ្យមានការផ្តល់នូវឯកសារច្រើនហួសហេតុ រួមទាំងព័ត៌មានអំពីធនាគាររបស់អង្គការផងដែរ។ ក្នុងករណីអង្គការក្នុងស្រុក លក្ខន្តិកៈគ្រប់គ្រងលំអិតមួយដែលមានចែងអំពី "ប្រភពនៃធនធាន និងទ្រព្យសម្បត្តិ" រួម ទាំងវិធានសម្រាប់គ្រប់គ្រងធនធាន និងទ្រព្យសម្បត្តិទាំងនោះ ត្រូវតែផ្តល់ទៅឲ្យក្រសួងមហាផ្ទៃ។ អង្គការអន្តរជាតិត្រូវបានតម្រូវឲ្យផ្តល់នូវលិខិត និងឯក

---

[2] របាយការណ៍របស់អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម Maina Kiai, UN Doc. A/HRC/20/27, ថ្ងៃទី 21 ខែឧសភា ឆ្នាំ 2012, កថាខណ្ឌ 56។ សូមអានផងដែរនូវរបាយការណ៍របស់អ្នករាយការណ៍ពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស , Hina Jilani, UN Doc. A/59/401, ថ្ងៃទី 1 ខែតុលា ឆ្នាំ 2004, កថាខណ្ឌ 82(ក): "តំណាងពិសេសជឿជាក់ថាការចុះបញ្ជីអង្គការមិនត្រូវជាការចាប់បង្ខំនោះទេ។ គេត្រូវឲ្យមានវត្តមានរបស់ NGOs ដើម្បីពួកគេអនុវត្តនូវសកម្មភាពរួមដោយមិនចាំបាច់ត្រូវចុះបញ្ជីអង្គការ ប្រសិនបើពួកគេមិនប្រាថ្នាចង់ចុះទេនោះ"។

[3] អ្នករាយការណ៍ពិសេសអំពីសិទ្ធិសេរីភាពប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម ចាត់ទុកថាជាច្បាប់អនុវត្តដ៏ប្រសើរបំផុត ដែលតម្រូវមិនឲ្យមានបុគ្គលលើសពី ២នាក់ចូលរួមបង្កើតសមាគម។ សូមអាន របាយការណ៍របស់អ្នកនាំពាក្យពិសេសអំពីសិទ្ធិសេរីភាពប្រមូលផ្តុំដោយសន្តិភាព និងសិទ្ធិសេរីភាពខាងសមាគម Maina Kiai, UN Doc. A/HRC/20/27, ថ្ងៃទី 21 ខែ ឧសភា ឆ្នាំ 2012, កថាខណ្ឌ 54។

សារដទៃទៀតដែលមានបញ្ជាក់អំពីថវិកាសម្រាប់គម្រោងរយៈពេល ៦ ខែ រួមទាំងលិខិតគាំទ្រ សម្រាប់គ្រប់គម្រោងទាំងអស់ពីក្រសួងរដ្ឋាភិបាល ឬស្ថាប័នរដ្ឋាភិបាល។ សេចក្តីព្រាងច្បាប់នេះ បានបញ្ចូលនូវកាតព្វកិច្ចជាបន្តបន្ទាប់សម្រាប់អង្គការក្នុងស្រុក និងអង្គការអន្តរជាតិក្នុងការជូនដំណឹងដល់អាជ្ញាធរក្នុងរយៈពេល ១៥ថ្ងៃនូវការផ្លាស់ប្តូរថ្នាក់ដឹកនាំ ទីតាំងការិយាល័យ និងខ្លឹមសារនៃលក្ខន្តិកៈគ្រប់គ្រងរបស់អង្គការ/សមាគម រួមទាំងឯកសារផ្សេងទៀត។ លក្ខខណ្ឌទាំងនេះគឺជាឧបស័គ្គដ៏ធំធេងមួយ និងមិនទំនងបម្រើឲ្យផលប្រយោជន៍ស្របច្បាប់ណាមួយ ដូចដែលមានចែងនៅក្នុងលក្ខខណ្ឌកំហិត ស្របតាមមាត្រា ២២ នៃកតិការសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR)។

*ការបដិសេធតាមទំនើងចិត្តនូវការចុះបញ្ជីអង្គការ/សមាគម៖* សេចក្តីព្រាងច្បាប់នេះ បានផ្តល់នូវឆន្ទានុសិទ្ធិពេញលេញដល់ក្រសួងមហាផ្ទៃ និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិក្នុងការធ្វើសេចក្តីសម្រេចថាតើ ទទួល ឬមិនទទួល ឬបដិសេធនូវពាក្យសុំចុះបញ្ជីរបស់អង្គការក្នុងស្រុក និងអង្គការអន្តរជាតិ ដោយមិនបានបញ្ជាក់អំពីលក្ខខណ្ឌវិនិច្ឆ័យនៃគោលបំណងដើម្បីតម្រង់ទិសដល់ដំណើរការនៃការកំណត់នេះ។

ក្រសួងមហាផ្ទៃ មានឆន្ទានុសិទ្ធិក្នុងការកំណត់ថាតើពាក្យសុំរបស់អង្គការក្នុងស្រុក មួយ "មិនបានបំពេញតាមលក្ខខណ្ឌសម្រាប់ចុះបញ្ជិកា" និងមានជម្រើសបន្ថែមក្នុងការបដិសេធពាក្យសុំរបស់អង្គការក្នុងស្រុកដែលមានគោលបំណង និងគោលដៅ "អាចធ្វើឲ្យប៉ះពាល់ដល់សន្តិសុខស្ថិរភាព និងសណ្តាប់ធ្នាប់សាធារណៈ ឬបង្កឲ្យមានការ គម្រាមកំហែងដល់សន្តិសុខជាតិ ឯកភាពជាតិ ឬវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា"។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវពិនិត្យមើលខ្លឹមសារនៃឯកសារ ដែលបានផ្តល់ឲ្យដោយសមាគម ឬអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ និងត្រូវ "សម្រេចថាតើខ្លួនមានបំណងចុះ ឬមិនចុះអនុស្សារណៈ" ជាមួយអង្គការនោះដែរឬយ៉ាងណា" ដែលអនុស្សារណៈនេះគឺជាឯកសារដ៏ចាំបាច់មួយសម្រាប់អង្គការអន្តរជាតិធ្វើប្រតិបត្តិការនៅក្នុងប្រទេសកម្ពុជា។

ក្នុងករណីដែលសមាគមក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាលមិនបានបំពេញនូវលក្ខខណ្ឌទាំងឡាយនៅក្នុងពាក្យសុំជាលាយលក្ខណ៍អក្សរទេនោះ ក្រសួងមហាផ្ទៃត្រូវជូន ដំណឹងជាលាយលក្ខណ៍អក្សរដោយឲ្យធ្វើការកែតម្រូវពាក្យសុំ។ ទោះដូច្នេះក្តី សេចក្តីព្រាងច្បាប់នេះ មិនមានចែងអំពីកាតព្វកិច្ចក្នុងការផ្តល់នូវសេចក្តីពន្យល់ជាលាយលក្ខណ៍អក្សរមួយសម្រាប់ការបដិសេធនូវពាក្យសុំ ដែលបានកែតម្រូវរួចហើយ ថែមទាំងមិនមានចែងអំពីកាតព្វកិច្ចក្នុងការផ្តល់សេចក្តីពន្យល់ ក្នុងករណីដែលពាក្យសុំត្រូវបានបដិសេធដោយហេតុផលថាវា "អាចប៉ះពាល់ទៅលើសន្តិសុខ ស្ថិរភាព និង សណ្តាប់ធ្នាប់សាធារណៈ" ។ល។ ដូចគ្នានេះផងដែរ មិនមានការចែងអំពីកាតព្វកិច្ចតម្រូវឲ្យក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិផ្តល់នូវកំណត់ពន្យល់ជាលាយលក្ខណ៍អក្សរ ដល់

សមាគមអន្តរជាតិ ឬអង្គការមិនមែនរដ្ឋាភិបាលដែល (ក្នុងករណី) ពាក្យសុំចុះអនុស្សារណៈរបស់ពួកគេត្រូវបានបដិសេធ។

ក្នុងករណីដែលសមាគមក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាលមានសិទ្ធិប្តឹងជំទាស់ទៅនឹងការបដិសេធចុះបញ្ជិការបស់ក្រសួងមហាផ្ទៃ សេចក្តីព្រាងច្បាប់មិនមានចែងអំពីសិទ្ធិប្តឹងជំទាស់ដូចគ្នានេះរបស់អង្គការអន្តរជាតិ (ក្នុងករណី) ដែលពាក្យសុំចុះអនុស្សារណៈរបស់ពួកគេត្រូវបានបដិសេធដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិនោះឡើយ។

បទប្បញ្ញត្តិទាំងនេះ មានភាពស្រពិចស្រពិល និងអនុញ្ញាតឲ្យមានការធ្វើការបដិសេធដ៏ខ្លាំងក្លានូវការចុះបញ្ជីអង្គការ/សមាគម ដោយការលើកហេតុផលតាមទំនើងចិត្ត។[4]
ទឡ្ហីករណ៍មួយចំនួនដែលត្រូវបានលើកជាហេតុផល សម្រាប់ការបដិសេធពាក្យសុំចុះបញ្ជីរបស់សមាគមក្នុងស្រុក ឬអង្គការមិនមែនរដ្ឋាភិបាល ដូចជាការរក្សាឯកភាពជាតិ ឬការការពារវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា គឺមានលក្ខណៈទូលំទូលាយជ្រុលនិងមិនបានបញ្ជាក់នូវផលប្រយោជន៍ស្របច្បាប់ដូចដែលមានចែងនៅក្នុងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងនយោបាយ (ICCPR) ឡើយ។

***លក្ខខណ្ឌតម្រូវឲ្យមានអព្យាក្រិតភាពខាងនយោបាយ៖*** សេចក្តីព្រាងច្បាប់នេះតម្រូវឲ្យអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ រួមទាំងសមាគម "គោរពជំហរ អព្យាក្រិតចំពោះគ្រប់គណបក្សនយោបាយ" ហើយសេចក្តីព្រាងច្បាប់នេះ មានចែងអំពីការព្យួរ និងការរំលាយចោលនូវក្រុមដែលរំលោភបំពានលើបទប្បញ្ញត្តិនេះ។ លក្ខខណ្ឌទាក់ទងនឹងអព្យាក្រិតភាពខាងនយោបាយនេះ បើកចំហរទ្វារសម្រាប់ការដាក់កំហិតតាម ទំនើងចិត្តរបស់រដ្ឋាភិបាលមកលើអង្គការទាំងឡាយ ដែលចូលរួមនៅក្នុងសកម្មភាពតស៊ូ មតិ ឬធ្វើការទិះតៀនដល់សកម្មភាពរបស់រដ្ឋាភិបាលដែលរារាំងយ៉ាងខ្លាំងនូវការទិះតៀនដ៏ស្របច្បាប់ទៅលើដំណើរការនយោបាយ សេចក្តីព្រាងច្បាប់និងគោលនយោបាយទាំងឡាយ។ ខៈណៈពេលដែលការធ្វើបែបនេះ វាជាការរំលោភបំពានទៅលើសេរីភាពខាងសមាគម វាក៏មានការរំលោភបំពានផងដែរទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។[5]

---

[4] តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្សបានបញ្ជាក់ថា "ច្បាប់អង្គការមិនមែនរដ្ឋាភិបាលត្រូវចែងព័ត៌មានឲ្យបានច្បាស់ និងអាចរកបានអំពីដំណើរការចុះបញ្ជិកាអង្គការ" ព្រមទាំងថា "សេចក្តីសម្រេចក្នុងការបដិសេធការចុះបញ្ជីអង្គការ ត្រូវតែមានការពន្យល់ឲ្យបានពេញលេញ"។ សូមអានរបាយការណ៍របស់តំណាងពិសេសរបស់អគ្គលេខាធិការអង្គការសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស , Hina Jilani, UN Doc. A/59/401, ថ្ងៃទី 1 ខែតុលា ឆ្នាំ 2004, កថាខណ្ឌ 82 (ឃ) និង (ង)។

[5] អ្នករាយការណ៍ពិសេសស្តីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម បានបញ្ជាក់ថា "សមាគមត្រូវទទួលបាននូវសិទ្ធិក្នុងការបញ្ចេញមតិ ផ្សព្វផ្សាយព័ត៌មាន ចូលរួមជាមួយសាធារណៈជន និងធ្វើការតស៊ូមតិទៅរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិសម្រាប់សិទ្ធិមនុស្ស សម្រាប់ការថែរក្សា និងការអភិវឌ្ឍរបស់អ្នកភាគតិច"។

*លក្ខខណ្ឌតម្រូវឲ្យធ្វើរបាយការណ៍ដែលបង្កនូវក្ដីព្រួយបារម្ភ៖* សេចក្ដីព្រាងច្បាប់ ចែងនូវរបបរាយការណ៍សម្រាប់អង្គការក្នុងស្រុក និងសមាគមអន្តរជាតិ និងអង្គការមិនមែន រដ្ឋាភិបាលអំពីសកម្មភាព និងហិរញ្ញវត្ថុទាំងឡាយ។ កាតព្វកិច្ចរាយការណ៍ដែលមានលក្ខណៈស្មុគ្រស្មាញ រួមមានការធ្វើរបាយការណ៍ផ្ញើជូនទៅក្រសួងមួយចំនួនមានក្រសួង មហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដោយអង្គការក្នុងស្រុក និងក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងសមាគមអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលត្រូវបានតម្រូវឲ្យ ផ្ដល់ដល់អាជ្ញាធរនូវកិច្ចព្រមព្រៀងទាំងឡាយដែលបានចុះជាមួយម្ចាស់ជំនួយ ដែលមាន ចែងអំពីកម្មវិធីការងារ និងការគាំទ្រហិរញ្ញវត្ថុ ក៏ដូចជា របាយការណ៍ប្រចាំឆ្នាំដែលបានផ្ញើ ទៅម្ចាស់ជំនួយផងដែរ។ ក្នុងករណីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ពួកគេត្រូវបានតម្រូវឲ្យដាក់របាយការណ៍ប្រចាំឆ្នាំស្ដីពីសកម្មភាព និងហិរញ្ញវត្ថុ។ ក្រសួងមហាផ្ទៃអាចស្នើ សុំរបាយការណ៍ប្រចាំឆ្នាំស្ដីពីសកម្មភាព និងហិរញ្ញវត្ថុពីសមាគមក្នុងស្រុក "ក្នុងករណីចាំបាច់"។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ឬអាជ្ញាធរសវនកម្មជាតិអាច "ធ្វើការពិនិត្យ និងធ្វើសវនកម្ម" ទៅលើសមាគមអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល "ក្នុងករណីចាំបាច់"។ ពាក្យថា "ក្នុងករណីចាំបាច់" មិនបានកំណត់និយមន័យនៅក្នុងសេចក្ដីព្រាងច្បាប់នេះឡើយ ហើយវាមានលក្ខណៈស្រពិចស្រពិល និងទូលំទូលាយជ្រុលដែលបើកចំហរឲ្យមានការធ្វើបំពាន។ របបដ៏ស្មុគ្រស្មាញ និងការិយាល័យធិបតេយ្យនេះ វាមិនចាំបាច់ ហើយវាតម្រូវឲ្យមានការរាយការណ៍មួយ ក្នុងកម្រិតដែលមិនបម្រើឲ្យផលប្រយោជន៍ស្របច្បាប់ទាល់តែសោះ។

*ការព្យួរ ការរំលាយចោល និងការបញ្ចប់សុពលភាពអនុស្សារណៈ* ៖ សេចក្ដីព្រាងច្បាប់មានបញ្ចូលនូវបទប្បញ្ញត្តិ ដែលមានលក្ខណៈជាការបោសសម្អាត ដោយមានចែងអំពីការព្យួរ និងការរំលាយចោលសមាគមក្នុងស្រុក និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងអនុញ្ញាតឲ្យមានការបញ្ចប់សុពលភាពអនុស្សារណៈដែលបានធ្វើដោយសមាគមអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។ វិធានការបែបនេះអាចប្រកាន់យកដោយក្រសួងមហាផ្ទៃ ឬក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្នុងករណីដែលអង្គការទាំងនោះរំលោភលើគោលការណ៍ "អព្យាក្រឹតភាព" ខកខានមិនបានបំពេញតាមលក្ខខណ្ឌនៃការធ្វើរបាយការណ៍របស់ខ្លួន បានធ្វើសកម្មភាព "ដែលប៉ះពាល់ដល់សន្តិសុខ ស្ថិរភាព និងសណ្ដាប់ធ្នាប់សាធារណៈ ឬ បង្កនូវការគម្រាមកំហែងដល់សន្តិសុខជាតិ ឯកភាពជាតិ ឬវប្បធម៌

---

សូមអានរបាយការណ៍របស់អ្នករាយការណ៍ពិសេសស្ដីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្ដុំដោយសន្តិវិធី និងសិទ្ធិសេរីភាពខាងសមាគម Maina Kiai, UN Doc. A/HRC/20/27, ថ្ងៃទី 21 ខែឧសភា ឆ្នាំ 2012, កថាខណ្ឌ 64។

ប្រពៃណី និងទំនៀមទម្លាប់របស់សង្គមជាតិកម្ពុជា" ឬរំលោភលើលក្ខន្តិកៈ អនុស្សារណៈរបស់ខ្លួន។ បទប្បញ្ញត្តិ ដែលមានលក្ខណៈជាការបោសសម្អាតទាំងនេះ ខ្វះនូវការរក្សាការពារបែបនីតិវិធី និង មិនមានភាពចាំបាច់ ព្រមទាំងវាត្រូវបានគេកំណត់មិនច្បាស់លាស់ដោយបើកផ្លូវឲ្យមានការបំពាន។ ឧទាហរណ៍ មាត្រា ៣៥ នៃសេចក្តីព្រាងច្បាប់នេះចែងអំពីការបញ្ចប់ដោយមិនមានការជូនដំណឹង និង ដោយមិនមានសិទ្ធិប្តឹងជំទាស់ទៅលើអនុស្សារណៈជាមួយសមាគមបរទេស ឬអង្គការមិនមែន រដ្ឋាភិបាល ដែល "មិនបានធ្វើសកម្មភាពសមស្របជាមួយអនុស្សារណៈនេះ"។

សេចក្តីព្រាងច្បាប់នេះ គឺជាឯកសារដ៏ខុសឆ្គងធ្ងន់ធ្ងរមួយដែលគួរតែដកចេញជា បន្ទាន់ ដោយរដ្ឋសភាជាតិ។ សេចក្តីប្រកាសសហប្រជាជាតិស្តីពីអ្នកការពារសិទ្ធិមនុស្ស បានអះអាង បញ្ជាក់ថា ការទទួលខុសត្រូវ និងភារកិច្ចជាចម្បងក្នុងការលើកកម្ពស់ និងការពារសិទ្ធិមនុស្ស និង សេរីភាពជាមូលដ្ឋានគឺជាភារកិច្ច និងការទទួលខុសត្រូវរបស់រដ្ឋ។ ប្រសិនបើសេចក្តីព្រាងច្បាប់នេះ ត្រូវបានអនុម័ត រដ្ឋាភិបាលនឹងរំលោភសិទ្ធិសេរីភាពខាងសមាគម ដែលជាសិទ្ធិមួយត្រូវបានធានា ចំពោះបុគ្គលគ្រប់រូបដោយច្បាប់សិទ្ធិមនុស្សអន្តរជាតិ និងសិទ្ធិចូលរួមយ៉ាងសកម្មនៅក្នុងជីវិតនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដែលជាសិទ្ធិមួយត្រូវបានធានានៅក្នុងមាត្រា ៣៥នៃរដ្ឋធម្មនុញ្ញ របស់ប្រទេសកម្ពុជា។

ដោយហេតុផលដូចបានជម្រាបជូនខាងលើ យើងខ្ញុំទាំងអស់គ្នាសូមអំពាវនាវដល់ រដ្ឋសភាជាតិមេត្តាដកចេញជាបន្ទាន់នូវសេចក្តីព្រាងច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនេះ និងអនុញ្ញាតឲ្យអង្គការសង្គមស៊ីវិលកម្ពុជាបន្តបំពេញការងារជាអ្នក ដើរតួនាទីដ៏សំខាន់នៅក្នុងការ ផ្តល់សេវាដ៏ចាំបាច់ ដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងធានានូវ ការការពារ និងលើកកម្ពស់នូវសិទ្ធិមនុស្សនៅក្នុងប្រទេសកម្ពុជា។

*ចុះហត្ថលេខាដោយៈ*

អង្គការអេកសិនអេដ (ActionAid)

ទីភ្នាក់ងារសម្រាប់សហប្រតិបត្តិការបច្ចេកទេស និងអភិវឌ្ឍន៍ (ACTED)

អង្គការលើកលែងទោសអន្តរជាតិ Amnesty International

បណ្តាញប្រជាធិបតេយ្យអាស៊ី Asian Democracy Network (AND)

វេទិកាអាស៊ីដើម្បីសិទ្ធិមនុស្សនិងការអភិវឌ្ឍ (FORUM-ASIA)

អង្គការឃែអន្តរជាតិនៅកម្ពុជា CARE International in Cambodia

ទីភ្នាក់ងារកាតូលិកសម្រាប់ការអភិវឌ្ឍនិអន្តរជាតិ (CAFOD)

អង្គការអ្នកការពារសិទ្ធិពលរដ្ឋ Civil Rights Defenders (CRD)

អង្គការជំនួយព្រះវិហារដាន / ជំនួយគ្រីស្ទាន Dan Church Aid / Christian Aid (DCA/CA)

អង្គការដាយកូនា Diakonia

អង្គការកុមារ និងការអភិវឌ្ឍន៍ Enfants & Développement

អង្គការហ្វាយអានអន្តរជាតិ FIAN International

អង្គការជំនួយពញរះវិហារហ្វិន Finn Church Aid

អង្គការហ្វ័រុំស៊ីត Forum Syd

អង្គការឃ្លាំមើលពិភពលោក Global Witness

អង្គការហ៊ិនរិចបុលស្ទីផុង Heinrich Böll Stiftung

អង្គការឃ្លាំមើលសិទ្ធិមនុស្ស Human Rights Watch (HRW)

គម្រោងគណនេយ្យភាពអន្តរជាតិ International Accountability Project (IAP)

គណៈកម្មាធិការចៅក្រមអន្តរជាតិ International Commission of Jurists (ICJ)

អង្គការវិនិយោគដើម្បីកុមារនិងសង្គមកុមារ Investing in Children and their Societies (ICS)

អង្គការអ៊ិហ្វិច IFEX

អង្គការឃ្លាំមើលសិទ្ធិមេធាវី កាណាដា Lawyers' Rights Watch Canada

អង្គការលីកាដូ កាណាដា LICADHO Canada (LC)

អង្គការជំនួយរបស់ពលរដ្ឋប្រទេសណករ៉េ Norwegian People's Aid (NPA)

អង្គការអ័កហ្វាម Oxfam

អង្គការប្រជាពលរដ្ឋដែលស្ថិតក្នុងសេចក្តីត្រូវការ People in Need (PIN)

អង្គការការពារអន្តរជាតិ Protection International (PI)

អង្គការសកម្មភាពកសិកម្មអាឡឺម៉ង់ Welthungerhilfe / German Agro Action

អង្គការក្តីសង្ឃឹមពិភពលោក World Hope International (WHI)

អង្គការពិភពលោកប្រឆាំងទារុណកម្ម World Organisation Against Torture (OMCT)